# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍របស់លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី អ្នករាយការណ៍ពិសេស អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២

ខ្ញុំជិតនឹងបញ្ចប់បេសកកម្មស្វែងរកការពិតអំពីសិទ្ធិមនុស្សលើកទីប្រាំបីរបស់ខ្ញុំ នៅព្រះរាជាណាចក្រកម្ពុជាហើយ ហើយអ្វីដែលខ្ញុំស្នើគួសបញ្ជាក់ គឺការរកឃើញជំហានដំបូងរបស់ខ្ញុំ និងការគិតគូរអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស។

សម្រាប់ជាកិច្ចចាប់ផ្តើម ខ្ញុំសូមចូលរួមរំលែកនូវព្រះមរណៈទុក្ខដ៏ក្រៀមក្រំរកទីបំផុតគ្មាន ចំពោះព្រះមហាវីរក្សត្រ ជាមួយរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទាំងមូល ចំពោះការសោយទីវង្គតរបស់ព្រះមហាវីរក្សត្រសម្តេចឪ។ នៅពេលដែលខ្ញុំចូលព្រះបរមរាជវាំង ដើម្បីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះបរមសពសម្តេចឪ ខ្ញុំយល់ឃើញថា ការសោយទីវង្គតនៃសម្តេចឪ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ គឺជាការបាត់បង់មួយដ៏ធំ មិនត្រឹមតែចំពោះប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះសហគមន៍អន្តរជាតិទាំងមូលផងដែរ។

ចាប់តាំងពីខ្ញុំទទួលបានការតែងតាំងពីក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក្នុងខែមីនា ឆ្នាំ២០០៩ មក ខ្ញុំបានធ្វើរបាយការណ៍សំខាន់ធំៗចំនួនបួន ដោយបានធ្វើការវិភាគជាលំអិតអំពីស្ថានភាពសិទ្ធិមនុស្ស និងបញ្ហាប្រឈមដែលប្រទេសកម្ពុជាជួបប្រទះ ទាក់ទងនឹងការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស។ របាយការណ៍ប្រចាំឆ្នាំរបស់ខ្ញុំ ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានផ្តោតជាសំខាន់លើប្រព័ន្ធយុត្តិធម៌ រដ្ឋសភាជាតិ និងកំណែទម្រង់ប្រព័ន្ធបោះឆ្នោត និងផលប៉ះពាល់លើសិទ្ធិមនុស្សដោយសម្បទានគោលដៅសេដ្ឋកិច្ច និងសម្បទានដទៃផ្សេងទៀត។ របាយការណ៍របស់ខ្ញុំបញ្ចូលនូវបណ្តុំអនុសាសន៍ ដើម្បីជួយដល់រាជរដ្ឋាភិបាល ស្របតាមរបៀបវារៈនៃកំណែទម្រង់របស់ខ្លួន និងដំណើរការប្រជាធិបតេយ្យូបនីយកម្មនៅក្នុងប្រទេស។ ជាជាងការផ្តោតលើប្រធានបទថ្មីមួយអំពីសិទ្ធិមនុស្សនៅក្នុងដំណើរបេសកកម្មលើកនេះរបស់ខ្ញុំ ខ្ញុំបានសំរេចចិត្ត ផ្តោតលើការឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសនិងតាមដានការអនុវត្តអនុសាសន៍ទាំងឡាយដែលមាននៅក្នុងរបាយការណ៍លើកមុនៗរបស់ខ្ញុំ។

នៅក្នុងអំឡុងពេលបំពេញបេសកកម្មរបស់ខ្ញុំ ខ្ញុំបានប្រស័យទាក់ទងជាមួយដៃគូពាក់ព័ន្ធទាំងឡាយនៅក្នុងសង្គមកម្ពុជា រាប់ទាំងសង្គមស៊ីវិល សហគមន៍មូលដ្ឋាន បុគ្គលឯកជន និងដៃគូអភិវឌ្ឍន៍របស់កម្ពុជា។ ខ្ញុំបានធ្វើដំណើរទៅខេត្តកំពង់ឆ្នាំង និងបានទទួលព័ត៌មានពីសហគមន៍មូលដ្ឋាននានា អំពីស្ថានភាពសិទ្ធិមនុស្ស។ ខ្ញុំមានការសោកស្តាយជាខ្លាំង ដែលខ្ញុំមិនអាចជួបប្រាស្រ័យទាក់ទងជាមួយដៃគូពិភាក្សាក្នុងជួររដ្ឋាភិបាល នាពេលនេះ ប៉ុន្តែខ្ញុំសង្ឃឹមថានឹងបានជួបពិភាក្សានៅអំឡុងពេលបំពេញបេសកកម្មរបស់ខ្ញុំនាថ្ងៃខាងមុខ។ ខ្ញុំមិនដឹងច្បាស់ទេថា ហេតុអ្វីបានជាស្ថានភាពនេះកើតឡើងយ៉ាងដូច្នេះ ហើយតើមកពីហេតុអ្វី។ អាណត្តិការងារសំខាន់ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រគល់ឲ្យខ្ញុំ គឺ ការឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស និងរាយការណ៍ជាសាធារណៈទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នោះគឺជាកិច្ចការដែលខ្ញុំបានធ្វើនៅក្នុងអំឡុងពេលនៃដំណើរបេសកកម្មរបស់ខ្ញុំ ហើយខ្ញុំនឹងសរសេររបាយការណ៍ នៅក្នុងពេលវេលាមួយសមស្រប។

ខ្ញុំជឿជាក់ថាការសន្ទនាគឺជាមធ្យោបាយមួយដ៏សំខាន់ឆ្ពោះទៅមុខ ហើយខ្ញុំបានបញ្ជាក់ម្តងហើយម្តងទៀតអំពីសារៈសំខាន់នៃការសន្ទនានេះ ជាមួយដៃគូពាក់ព័ន្ធទាំងអស់ ហើយជាពិសេស រាជរដ្ឋាភិបាល។ នៅរាល់ដំណើរបេសកកម្មទាំងអស់របស់ខ្ញុំ ខ្ញុំបានប្រាស្រ័យទាក់ទងជាមួយតួអង្គផ្សេងៗក្នុងសង្គមកម្ពុជា រាប់ទាំងរាជរដ្ឋាភិបាល សមាជិករដ្ឋសភា តុលាការ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ហើយមានកាលៈទេសៈខ្លះ យើងមិនបានឯកភាពគ្នាលើបញ្ហាមួយចំនួន។ ប៉ុន្តែយើងបានបន្តធ្វើការសន្ទនារបស់យើង ដើម្បី ស្វែងរកការព្រមព្រៀងគ្នាជារួមមួយ ដែលនោះហើយគឺជាអ្វីដែលខ្ញុំប្រាថ្នាចង់ធ្វើការជាមួយរាជរដ្ឋាភិបាល យ៉ាងដូច្នោះដែរ។

ខ្ញុំបានប្រកាន់ភ្ជាប់នូវគោលការណ៍សន្ទនាក្នុងន័យស្ថាបនា ក្នុងការបំពេញអាណត្តិការងាររបស់ខ្ញុំ ហើយនឹង បន្តធ្វើដូចនេះតទៅទៀត ។ គោលដៅរបស់ខ្ញុំ គឺការផ្តល់ប្រឹក្សាយោបល់សម្រាប់អនាគតនៃប្រទេសនេះ មានសុខសន្តិភាព ប្រជាធិបតេយ្យ ស្ថិរភាព និងនិរន្តរភាព ហើយអនុសាសន៍របស់ខ្ញុំ ធ្វើឡើងដើម្បីផ្តល់ជូនជាដំណោះស្រាយចំពោះបញ្ហាប្រឈមមួយចំនួនខាងសិទ្ធិមនុស្សក្នុងប្រទេសនេះ។

កម្ពុជាបន្តអនុវត្តបានល្អលើសូចនាករជាច្រើនក្នុងវិស័យសេដ្ឋកិច្ច គ្រាំទ្រដោយស្ថិរភាពនយោបាយ។ ប្រទេសកម្ពុជាទំនងជាកំពុងស្ថិតនៅលើផ្លូវមួយឈានទៅសម្រេចជោគជ័យលើវិស័យមួយចំនួននៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ សិទ្ធិលើដីធ្លីបានក្លាយជា បញ្ហាដ៏ធំមួយក្នុងប្រទេសនេះ។ ជាមួយនឹងអង្គការសិទ្ធិមនុស្ស សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ខ្ញុំបានធ្វើការអំពាវនាវសូមឲ្យពន្លឿនការអនុវត្តកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ប្រកបដោយភាពត្រឹមត្រូវ និងតម្លាភាព ជូនប្រជាពលរដ្ឋកម្ពុជា។ ចាប់តាំងពីដំណើរបេសកកម្មលើកមុនរបស់ខ្ញុំ រាជរដ្ឋាភិបាល បានអនុវត្តកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ក្នុងគោលបំណងផ្តល់សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីដល់ប្រជាពលរដ្ឋកម្ពុជារាប់ពាន់នាក់។ នៅអំឡុងពេលទស្សនកិច្ចរបស់ខ្ញុំនៅខេត្តកំពង់ឆ្នាំង កាលពីថ្ងៃច័ន្ទ ខ្ញុំបានឃើញ អ្នកភូមិជាច្រើនមានទឹកមុខញញឹមរីករាយ ដែលទទួលប័ណ្ណកម្មសិទ្ធិដីធ្លី ដែលពួកគាត់បានទន្ទឹងរង់ចាំជាយូរមកហើយ ។ ជាការពិតណាស់ មានកង្វល់ជាច្រើនអំពីការអនុវត្តកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិ

ដីធ្លីនេះ ដូចជាកង្វះតម្លាភាព ផលប៉ះពាល់របស់ កម្មវិធីនេះទៅលើជនជាតិដើមភាគតិច និងអំពីរបៀបជ្រើសរើសសហគមន៍ ដែលត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ឲ្យតែកម្មវិធីនេះអាចផ្តល់ឲ្យម្ចាស់ដីស្របច្បាប់ ទទួលបានកម្មសិទ្ធិដីធ្លីរបស់ខ្លួនស្របច្បាប់នោះ វាគឺជាវឌ្ឍនភាពមួយដែលត្រូវស្វាគមន៍ហើយ។

ខ្ញុំបានប្រាស្រ័យទាក់ទងយ៉ាងល្អជាមួយដៃគូពាក់ព័ន្ធផ្សេងៗលើវិស័យសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត ដែលជាប្រធានបទនៃរបាយការណ៍ចុងក្រោយរបស់ខ្ញុំ។ នៅព្រឹកនេះ ខ្ញុំបានរៀបចំកិច្ចប្រជុំមួយ ដើម្បីផ្តោតលើការស្វែងរកដំណោះស្រាយមួយមានតុល្យភាពចំពោះបញ្ហាទាំងឡាយ ដែលទាក់ទងនឹងសម្បទានទាំងនេះ។

ខ្ញុំជឿជាក់ថា អនុសាសន៍ទាំងឡាយ ដែលខ្ញុំបានផ្តល់ជូននៅក្នុងរបាយការណ៍មុនៗរបស់ខ្ញុំ គឺមានផលប្រយោជន៍ល្អបំផុតសំរាប់ប្រទេសកម្ពុជា និងជាមូលដ្ឋាន មិនត្រឹមតែទៅលើការយល់ឃើញជាទូទៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅលើកាតព្វកិច្ចទាំងឡាយរបស់កម្ពុជាដែលស្ថិតនៅក្រោមសន្ធិសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ដែលប្រទេសនេះបានផ្តល់សច្ចាប័នដោយស្ម័គ្រចិត្ត និងទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ភារកិច្ចរបស់ខ្ញុំ គឺត្រូវចង្អុលបង្ហាញអំពីកាតព្វកិច្ចដែលកើតចេញពីសន្ធិសញ្ញាទាំងនេះ និងលិខិតបទដ្ឋាននានាស្តីពីលទ្ធិប្រជាធិបតេយ្យសេរីដែលត្រូវបានទទួលយកជាអន្តរជាតិ នីតិរដ្ឋ និងពហុបក្ស និង ដើម្បីជួយដល់រាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន។ ប្រទេកម្ពុជាគឺជាសមាជិកដ៏សំខាន់មួយរបស់អង្គការសហប្រជាជាតិ ហើយបានយល់ព្រមអនុវត្តតាមលិខិតបទដ្ឋានសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ អ្វីដែលខ្ញុំកំពុងតែព្យាយាមធ្វើ គឺជាផ្នែកមួយនៃការងាររបស់ខ្ញុំក្នុងនាមអង្គការសហប្រជាជាតិ គឺត្រូវផ្តល់យោបល់ជូនរាជរដ្ឋាភិបាល អំពីអ្វីដែលជាកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ និងផ្តល់ជាមតិយោបល់អំពីមធ្យោបាយមួយ ដែលត្រូវអនុវត្តទៅមុខទៀតក្នុងនាមខ្ញុំជាអ្នកជំនាញការឯករាជ្យមួយរូបរបស់អង្គការសហប្រជាជាតិ។

ចំណុចដែលខ្ញុំចង់បញ្ជាក់នោះគឺថា ប្រទេសនេះ មានគោលនយោបាយមួយច្បាស់លាស់រួចហើយក្នុងការបន្តដំណើរនៅលើផ្លូវមួយឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋពិតប្រាកដ និងការគោរពសិទ្ធិមនុស្សកាន់តែរឹងមាំឡើងថែមទៀត ។ ដោយហេតុនេះ បញ្ហាសិទ្ធិមនុស្សទាំងឡាយ ដែលខ្ញុំបានលើកឡើងនៅក្នុងរបាយការណ៍របស់ខ្ញុំ គឺមិនយូរមិនឆាប់ គង់តែចាំបាច់ត្រូវដោះស្រាយនៅពេលណាមួយជាមិនខាន។

ជាការពិតណាស់ អនុសាសន៍ទាំងឡាយរបស់ខ្ញុំដែលលើកឡើង អំពីមធ្យោបាយក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ គឺគ្រាន់តែដាក់ជូនរាជរដ្ឋាភិបាល ដើម្បីធ្វើការពិចារណាតែប៉ុណ្ណោះ។ ខ្ញុំគោរពទាំងស្រុងចំពោះអធិបតេយ្យភាពរបស់ប្រទេសនេះ និងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្នុងការសំរេចចិត្ត ដើម្បីផលប្រយោជន៍ជាតិ។

ខ្ញុំបំពេញបេសសកម្មលើកទី៦របស់ខ្ញុំមកកាន់ប្រទេសកម្ពុជា ដោយផ្តោតលើបញ្ហាសិទ្ធិមនុស្សទាក់-ទងនឹងការបោះឆ្នោត និងជាថ្មីម្តងទៀត ផ្តោតការយកចិត្តទុកដាក់ចំពោះរបាយការណ៍របស់ខ្ញុំ ដែលផ្តោតលើ

កំណែទម្រង់នៃការបោះឆ្នោត ដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សកាលពីខែកញ្ញា ឆ្នាំ២០១២។ ខ្ញុំសូមជំរុញឲ្យគ្រប់ភាគីទាំងអស់ និងគណៈកម្មាធិការបោះឆ្នោតជាតិ ដើម្បីធានាឲ្យមានការបោះឆ្នោតដោយសេរី យុត្តិធម៌ និងសន្តិវិធី។ ខ្ញុំក៏សូមជំរុញផងដែរដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ អនុវត្តសិទ្ធិរបស់ខ្លួនដោយទទួលខុសត្រូវ និងការគោរពសិទ្ធិរបស់អ្នកដទៃឲ្យបានត្រឹមត្រូវ នៅពេលអនុវត្តសិទ្ធិរបស់ខ្លួនផ្ទាល់។

ការប្រព្រឹត្តទៅដោយត្រឹមត្រូវនៃស្ថាប័នតុលាការ គឺជាមូលដ្ឋានគ្រឹះនៃប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ មានការបង្ហាញមួយចំនួនដល់ខ្ញុំ ក្នុងអំឡុងពេលនៃបេសសកម្មនេះ អំពីឯករាជ្យភាព និងសមត្ថភាពនៃប្រព័ន្ធតុលាការ។ ដូចខ្ញុំបានបញ្ជាក់ក្នុងរបាយការណ៍ កាលពីឆ្នាំ២០១០ ស្តីពីស្ថាប័នតុលាការ ច្បាប់ជាមូលដ្ឋានទាំង៣ នឹងត្រូវបានតាក់តែងឡើង ដើម្បីធានាអំពីឯករាជ្យភាព និងលើកកំពស់សមត្ថភាពនៃស្ថាប័នតុលាការ ដែលបានអូសបន្លាយរយៈពេលដ៏យូរមកហើយ។ ជាអកុសល ការណ៍នេះនៅតែជាបញ្ហាចោទមកដល់ពេលបច្ចុប្បន្ននេះ។ ខ្ញុំសូមជំរុញដល់រាជរដ្ឋាភិបាល សូមពន្លឿនការអនុម័តច្បាប់ដ៏សំខាន់ទាំងនេះ។

ខ្ញុំនៅតែមានការព្រួយបារម្ភណ៍ជាខ្លាំងអំពី វប្បធម៌និទណ្ឌភាពនៅកម្ពុជា និងបញ្ជីដ៏វែងនៃបទឧក្រិដ្ឋដែលក្នុងនោះមិនមានជនល្មើសណាមួយត្រូវបាននាំខ្លួនមកតុលាការដើម្បីផ្តន្ទាទោសឡើយ។ និទណ្ឌភាពគឺជាមេរោគដែលស៊ីរូងសង្គម។ និទណ្ឌភាពធ្វើឲ្យបាត់បង់ទំនុកចិត្តរបស់សាធារណជនលើប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសមួយ ដែលមិនត្រឹមតែក្នុងប្រព័ន្ធតុលាការប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងស្ថាប័ននគរបាល និងភ្នាក់ងារប្រតិបត្តិច្បាប់ផ្សេងៗផងដែរ។

ខ្ញុំពិតជាមានការព្រួយបារម្ភជាខ្លាំងអំពីសេរីភាពក្នុងការបញ្ចេញមតិនៅក្នុងប្រទេស។ មានករណីមួយចំនួនទាក់ទងនឹងការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញដល់អ្នកដែលបំពេញការងារក្នុងវិស័យព័ត៌មាន និងតស៊ូមតិផ្នែកសិទ្ធិមនុស្ស ត្រូវបានរាយការណ៍មកខ្ញុំ។ ការប្រើប្រាស់ច្បាប់ស្តីពី "ការញុះញង់" ហួសហេតុហាក់បីដូចជាធ្វើឲ្យប្រជាពលរដ្ឋដាក់សម្ពាធលើខ្លួនដោយខ្លួនឯង។

ជាចុងបញ្ចប់ ខ្ញុំដឹងថា ប្រទេសទាំងមូលកំពុងតែចូលរួមរំលែកព្រះមរណៈទុក្ខ ចំពោះការសោយទីវង្គតរបស់សម្តេចឪ។ តាមទស្សនៈរបស់ខ្ញុំ នេះក៏ជាឱកាសមួយក្នុងការអបអរសាទរនូវអ្វី ដែលព្រះអង្គបានសម្រេចនៅក្នុងឆាកជីវិតរបស់ទ្រង់ ដើម្បីសន្តិភាព ស្ថិរភាព ការផ្សះផ្សាផ្នែកនយោបាយ ប្រជាធិបតេយ្យ នីតិរដ្ឋ និងសិទ្ធិមនុស្ស ព្រមទាំងអ្វីដែលប្រទេសកម្ពុជាបានសម្រេចដោយជោគជ័យ បន្ទាប់ពីការចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១។ នេះគឺជាពេលវេលា ក្នុងការសម្លឹងមើលទៅមុខដោយយកចិត្តទុកដាក់ និងបង្ហាញពីដំណោះស្រាយថ្មីមួយ ឈានទៅកាន់សុខដុមនីយកម្ម និងការផ្សះផ្សារជាតិ សម្រាប់ភាពល្អប្រសើរនៃប្រទេសជាតិ។ តាមទស្សនៈផ្ទាល់របស់ខ្ញុំ ភាពជាអ្នកដឹកនាំ និងភាពជារដ្ឋបុរស គឺជាការសន្ទនារវាងភាគីទាំងឡាយដោយស្មើភាពគ្នា និងបង្កើតឡើងនូវមតិព្រមព្រៀងគ្នាមួយ ព្រមទាំងការផ្សះផ្សានៃការប្រកួតប្រជែងគ្នាលើតម្លៃ និងផលប្រយោជន៍សំរាប់សុខមាលភាពនៃប្រទេសជាតិទាំងមូល។ តាមទស្សនៈផ្ទាល់របស់ខ្ញុំ ភាពជាអ្នកដឹកនាំ និងភាពជារដ្ឋបុរស គឺនិយាយអំពីការសន្ទនាប្រកបភាពប៉ិនប្រសប់។ គោលបំណងសំខាន់គឺដើម្បីកសាងមតិយល់ស្របគ្នាជាទូទៅ និងការផ្សះផ្សាការប្រកួតប្រជែងគ្នាអំពីតំលៃ និងផលប្រយោជន៍សំរាប់សុខមាលភាពនៃជាតិទាំងមូល។

ខ្ញុំត្រូវតែនិយាយថា ខ្ញុំមានការភ្ញាក់ផ្អើលបន្តិច ដោយបានឮប្រតិកម្មចំពោះអនុសាសន៍មួយចំនួនរបស់ខ្ញុំ។ នៅក្នុងប្រទេសផ្សេងៗ អនុសាសន៍ទាំងឡាយដូចនេះ ត្រូវបានគេឃើញថាជាផ្នែកមួយនៃការជជែកពិភាក្សាអំពីច្បាប់ជាតិ និងការពិភាក្សាដោយត្រង់ៗនិងប្រកបដោយវិជ្ជាជីវៈអាចនឹងត្រូវបានធានា។ គួរផ្តោតទៅលើខ្លឹមសារនៃអនុសាសន៍របស់ខ្ញុំ មិនគួរផ្តោតលើរូបខ្ញុំជាលក្ខណៈបុគ្គលនោះទេ។

ជាទីបញ្ចប់ ខ្ញុំសូមធ្វើការបូកសរុប ដោយការថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ដែលបានអញ្ជើញរូបខ្ញុំមកប្រទេសកម្ពុជា និងដែលមិនធ្វើឲ្យមានការរាំងស្ទះដំណើររបស់ខ្ញុំចូលជួបជាមួយជនរងគ្រោះដោយអំពើរំលោភបំពានសិទ្ធិមនុស្ស។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់សហគមន៍ដែលខ្ញុំបានទៅជួបដែលពួកគាត់បានទទួលស្វាគមន៍ខ្ញុំ ព្រមទាំងដល់ដៃគូសន្ទនាទាំងឡាយ និង សមាជិកសភា សង្គមស៊ីវិល ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស និងសហគមន៍អង្គទូតនៅរាជធានីភ្នំពេញ។ ដូចសព្វមួយដងការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ទាំងនៅទីក្រុងហ្សឺណែវ ទាំងនៅរាជធានីភ្នំពេញ បានផ្តល់ការជួយឧបត្ថម្ភផ្នែកភស្តុភារ និងបច្ចេកទេសដល់រូបខ្ញុំ ដែលអាចឲ្យខ្ញុំបំពេញការងារបាន។ ខ្ញុំសូមអរគុណដល់ពួកគាត់ទាំងអស់គ្នា។

**ចប់**

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូបេឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកមិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់ ។ បច្ចុប្បន្នលោកគឺជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស។*

*រាល់ការស្នើសុំព័ត៌មានទាក់ទងនឹងអ្នករាយការណ៍ពិសេស អាចផ្ញើទៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំកម្ពុជា។ សូមមេត្តាទំនាក់ទំនងមកកញ្ញា ហ្ស៊ូអ៊ី ឡាធំបូ តាមរយៈទូរស័ព្ទលេខ 012 790 178 អ៊ីម៉ែល* zlatumbo@ohchr.org *ឬ លោក ទូច ហួន តាមរយៈទូរស័ព្ទលេខ 012 476 493 អ៊ីម៉ែល* htouch@ohchr.org *។*